The Jean Hailes *Foundation for women's health*

# ការព្យាបាលដោយប្រើថ្នាំប៉ូវអ័រម៉ូន

**តើការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូនជាអ្វី?**
ការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូន (HT) ឬការប្រើអ័រម៉ូនបំពេញកង្វះខាត (HRT) គឺជាការប្រើថ្នាំអ័រម៉ូនអ៊ីស្ត្រូជិន និងអ័រម៉ូនប្រូជេស្តេរ៉ូន ដែលជាអ័រម៉ូនញី រួមជាមួយនឹងអ័រម៉ូនថេស្តូស្តេរ៉ូន ដែលជាអ័រម៉ូនឈ្មោល។

វេជ្ជបណ្ឌិតអាចចេញថ្នាំអ័រម៉ូននេះឲ្យស្ត្រីប្រើដើម្បីសំរាលនូវអាការៈទាំងឡាយ ដែលពាក់ព័ន្ធនឹងការធ្លាក់ចុះនៃកំរិតអ័រម៉ូន ជាពិសេសអ័រម៉ូនអ៊ីស្ត្រូជិន នៅក្នុងអំឡុងពេលអស់រដូវ មានដូចជាការក្តៅក្រហល់ក្រហាយក្នុងខ្លួន ភាពស្ងួតនៅក្នុងទ្វារមាស ការលេចនោមនៅពេលប្រឹងខ្លាំង ការទទួលទានដំណេកមិនបាន និងអារម្មណ៍ផ្លាស់ប្តូរមិនទៀងទាត់។ ការព្យាបាលដោយការប្រើអ័រម៉ូនក៏អាចការពារមិនឲ្យមានការបាក់ឆ្អឹងនៅក្នុងចំណោមស្ត្រីដែលមានបញ្ហាពុកឆ្អឹងផងដែរ នៅក្នុងខណៈដែលសារពាង្គកាយមិនអាចទ្រាំទ្រនឹងការព្យាបាលដទៃទៀតបាននោះ។

ចំពោះស្ត្រីដែលបាត់បង់ស្បូនដោយការវះកាត់ ពេទ្យអាចចេញវេជ្ជបញ្ជាឲ្យស្ត្រីនោះ ប្រើតែថ្នាំអ័រម៉ូនអ៊ីស្ត្រូជិនបាន។ ចំពោះស្ត្រីដែលនៅមានស្បូន ការប្រើតែអ័រម៉ូនអ៊ីស្ត្រូជិនមួយមុខអាចរំញោចកោសិកានៅតាមភ្នាសស្បូនខ្លាំងហួស ដែលអាចបង្កនូវលទ្ធភាពកាន់តែខ្លាំងឡើងក្នុងការកើតមានមហារីកនៅភ្នាសស្បូន។ លទ្ធភាពនៃគ្រោះថ្នាក់នេះអាចកាត់បន្ថយបានតាមរយៈការប្រើអ័រម៉ូនប្រូជេស្តេរ៉ូនរួមជាមួយនឹងអ័រម៉ូនអ៊ីស្ត្រូជិន។ គេស្គាល់ឬហៅ

អ័រម៉ូនប្រូជេស្តេរ៉ូនថា 'ប្រូជេស្ទិន' ឬ 'ប្រូជេស្តូជិន' ហើយពេទ្យចេញវេជ្ជបញ្ជាឲ្យប្រើថ្នាំនេះ ក្នុងទ្រង់ទ្រាយជាថ្នាំគ្រាប់ ឬក៏ជាបន្ទះកៅអៀកសំរាប់បិទ។

ពេទ្យអាចចេញវេជ្ជបញ្ជាឲ្យប្រើថ្នាំអ័រម៉ូនអ៊ីស្ត្រូជិនក្នុងទ្រង់ទ្រាយជាថ្នាំគ្រាប់ បន្ទះកៅអៀកសំរាប់បិទ ថ្នាំខាប់អន្ទិល ថ្នាំដាក់បង្កប់ចូលក្រោមស្បែក ថ្នាំចាក់ ថ្នាំក្រែម ថ្នាំសុល (ថ្នាំបន្សុល)។ កំរិតថ្នាំនិងវិធីផ្តល់ថ្នាំ មានលក្ខណៈខុសៗគ្នា ទៅតាមតម្រូវការរបស់បុគ្គលនីមួយៗ ហើយការផ្លាស់ប្តូរវិធីនិងកំរិតថ្នាំអាចកើតមានឡើង ទម្រាំតែគេរកឃើញវិធីនិងកំរិតសមប្រកបល្អនោះ។ សូមសាកសុំយោបល់ និងការគ្រប់គ្រងពីវេជ្ជបណ្ឌិតរបស់អ្នក។

**តើការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូននេះ អាចបង្កឲ្យមានទំនាស់អ្វីខ្លះ?**

ស្ត្រីខ្លះជួបប្រទះនឹង៖

- ការចង់ក្អួតចង្អោរ
- មានអារម្មណ៍ថាខ្លួនមានជាតិទឹកច្រើន
- សុដន់ឡើងរីកធំ និងមានលក្ខណៈទន់ងាយឈឺ
- ធ្លាក់ឈាមមុននិងក្រោយពេលមានរដូវ
- ឡើងទម្ងន់
- លទ្ធភាពនៃកំណកឈាមមានការកើនឡើង
- លទ្ធភាពនៃការកើតមានជំងឺបេះដូង និងដាច់សរសៃខួរក្បាល មានការកើនឡើងបន្តិច (ចំពោះស្ត្រីដែលឋិតនៅក្នុងវ័យអស់រដូវ និងស្ត្រីដែលកំពុងឆ្លងកាត់ការអស់រដូវ)

**តើការព្យាបាលដោយការប្រើអ័រម៉ូន 'រយៈពេលខ្លី' និង 'រយៈពេលយូរ' មានន័យយ៉ាងណា?**

ការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូនរយៈពេលខ្លី ជាទូទៅគឺមានរយៈពី១ឆ្នាំទៅ៥ឆ្នាំ។ រីឯការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូនរយៈពេលយូរវិញ គឺប្រើសំរាប់រយៈពេល៥ឆ្នាំ និងលើសពី៥ឆ្នាំ។ អាការៈធ្វើទុក្ខនៃការអស់រដូវអាចឈប់កើតមានតទៅទៀតចំពោះស្ត្រីជាច្រើនរូបនៅក្នុងរវាងពេល៥ឆ្នាំនៃការអស់រដូវ ហេតុដូច្នេះការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូនរយៈពេលខ្លី គឺជាការគ្រប់គ្រាន់ណាស់ទៅហើយជាទូទៅនោះ។

The Jean Hailes Foundation for Women's Health
*Education Unit*
PO Box 1108, Clayton South,
Victoria, Australia 3169
173 Carinish Road, Clayton,
Victoria, Australia 3168
ACN 092 915 618

*tel* (03) 9562 6771
*toll-free* 1800 151 441
*fax* (03) 9548 9120
*email* education@jeanhailes.org.au
*web* www.jeanhailes.org.au

# ការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូន

**តើខ្ញុំអាចប្រឈមមុខខ្លាំងឬទេ ទៅនឹងគ្រោះថ្នាក់នៃការកើតមានជំងឺមហារីកសុដន់ នៅពេលខ្ញុំទទួលការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូននោះ?**

ការសិក្សាស្រាវជ្រាវខ្លះដែលធ្វើការពិនិត្យមើលថា តើការព្យាបាលដោយការប្រើអ័រម៉ូនរយៈពេលខ្លី មានការពាក់ព័ន្ធជាមួយការប្រឈមមុខនឹងគ្រោះថ្នាក់កាន់តែខ្លាំងឡើងនៃការកើតមានមហារីកសុដន់ឬទេ បង្ហាញឲ្យដឹងអំពីកំណើនតិចតួចនៃគ្រោះថ្នាក់ជំងឺមហារីកនេះ ហើយការសិក្សាស្រាវជ្រាវខ្លះទៀតមិនបង្ហាញអំពីគ្រោះថ្នាក់អ្វីឡើយ។ សេចក្តីសំរេចចិត្តណាមួយអំពីការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូន គឺជារឿងផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ ហើយសេចក្តីសំរេចចិត្តនេះ គប្បីធ្វើឡើង ក្រោយពេលដែលស្ត្រីដឹងយល់អំពីលទ្ធភាពនានាពាក់ព័ន្ធនឹងគ្រោះថ្នាក់ ផលប្រយោជន៍ សេចក្តីត្រូវការ និងការបារម្ភទាំងពួង ដោយការប្រឹក្សាយោបល់ជាមួយនឹងវេជ្ជបណ្ឌិតខ្លួន។

សូមធ្វើការឆែកពិនិត្យសុដន់របស់ខ្លួនជាទៀងទាត់ និងទៅជួបវេជ្ជបណ្ឌិតប្រចាំគ្រួសារ ដើម្បីធ្វើតេស្តពិនិត្យមើលមាត់ស្បូនជារៀងរាល់២ឆ្នាំម្តង។ បើសិនជាអ្នកមានអាយុលើសពី៥០ឆ្នាំឡើងទៅ ការថតពិនិត្យមើលសុដន់ជារៀងរាល់២ឆ្នាំម្តងគឺជារឿងដែលត្រូវតែធ្វើជាចាំបាច់ (សេវាដោយឥតគិតថ្លៃមានជូនដោយ BreastScreen - លេខទូរស័ព្ទ 132 050)។

**តើនៅពេលណាដែលពេទ្យមិនណែនាំឲ្យមានការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូននោះ?**

ជាទូទៅនៅពេលដែលស្ត្រីណាមួយមាន៖

- ប្រវត្តិជំងឺមហារីក
- មហារីកស្បូនស្បូន
- ការធ្លាក់ឈាមតាមទ្វារមាស ដោយគ្មានហេតុផល
- បញ្ហាឈាមកក
- ប្រវត្តិកំណកឈាមនៅក្នុងសរសៃឈាម
- ប្រវត្តិ ឬលទ្ធភាពមានគ្រោះថ្នាក់កាន់តែខ្លាំងឡើងនៃជំងឺបេះដូង និងដាច់សរសៃខួរក្បាល ដោយរួមទាំងជំងឺទឹកនោមផ្អែម។

យ៉ាងណាមិញ ទោះបីជាមានបញ្ហាសុខភាពណាមួយនៅក្នុងចំណោមបញ្ហាដែលមានរៀបរាប់នៅខាងលើនេះក៏ដោយ ក៏ការព្យាបាលដោយ**ការប្រើថ្នាំប៉ូវអ័រម៉ូន អាចមានផលប្រយោជន៍ដល់ស្ត្រីខ្លះ បើសិនជាស្ត្រីមានការយល់ដឹងអំពីគ្រោះថ្នាក់ដែលអាចកើតមាន និងផលប្រយោជន៍ទាំងនោះ ឲ្យបានច្បាស់លាស់។**

ស្ត្រីដែលមានជំងឺថ្លើម ជំងឺប្រកាំង ប្រកាច់ឆ្កួតជ្រូក ទឹកនោមផ្អែម និងជំងឺថង់ទឹកប្រមាត់ មានដុំសាច់នៅក្នុងស្បូន និងការដុះសាច់ក្នាសស្បូននៅក្រៅស្បូន និងសម្ពាធឈាមឡើង (លើសឈាម) គឺសុទ្ធតែជាបញ្ហាត្រូវការការគិតគូរពិចារណា មុននឹងពេទ្យចេញវេជ្ជបញ្ជាឲ្យមានការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូន។

**តើខ្ញុំត្រូវសាកសួរវេជ្ជបណ្ឌិតរបស់ខ្ញុំអំពីអ្វីខ្លះទៅ?**

មុននឹងការចាប់ផ្តើមការព្យាបាលដោយការប្រើថ្នាំប៉ូវអ័រម៉ូន សូមស្វែងមើលជម្រើសនានារបស់អ្នក និងលទ្ធភាពនៃគ្រោះថ្នាក់ ក៏ដូចជាផលប្រយោជន៍ផងដែរ ពីវេជ្ជបណ្ឌិតរបស់អ្នក។ នៅពេលដែលពេទ្យចេញវេជ្ជបញ្ជាឲ្យមានការព្យាបាលដោយការប្រើថ្នាំអ័រម៉ូនហើយនោះ ការទៅជួបវេជ្ជបណ្ឌិតដើម្បីឆែកពិនិត្យសុខភាពគឺជារឿងចាំបាច់ បន្ទាប់ពី ២ទៅ៣ខែក្រោយមក ហើយកាឆែកពិនិត្យសុខភាពប្រចាំឆ្នាំក៏ជារឿងសំខាន់ចាំបាច់ដែរ។

**តើនរណាខ្លះដែលអាចទទួលផលប្រយោជន៍ពីការព្យាបាលដោយការប្រើអ័រម៉ូនថេស្តូស្តេរ៉ូន?**

ស្ត្រីដែលឆ្លងកាត់ការបាត់បង់ចំណង់រួមភេទ រួមជាមួយនឹងការអស់កម្លាំងអាចទទួលប្រយោជន៍ពីការព្យាបាលដោយប្រើអ័រម៉ូនថេស្តូស្តេរ៉ូន លុះតែណាអាការៈទាំងនេះ មិនមានការពាក់ព័ន្ធទៅនឹងកត្តាផ្លូវចិត្ត និង/ឬទំនាក់ទំនងសម្ព័ន្ធភាព។ ពេទ្យក៏អាចគិតគូរផងដែរអំពីការផ្តល់អ័រម៉ូនថេស្តូស្តេរ៉ូនទៅឲ្យស្ត្រីវ័យក្មេងដែលឆាប់អស់រដូវ ឬក្រោយពេលវះកាត់យកដៃស្បូនចេញ។

ពេទ្យផ្តល់អ័រម៉ូនថេស្តូស្តេរ៉ូនក្នុងទ្រង់ទ្រាយជាថ្នាំបង្កប់ចូលទៅក្រោមស្បែក ថ្នាំចាក់ ថ្នាំក្រែម ហើយជាទូទៅគឺចេញឲ្យប្រើសំរាប់តែរយៈពេលខ្លីប៉ុណ្ណោះ។ ពេទ្យអាចផ្តល់ថ្នាំអ័រម៉ូនថេស្តូស្តេរ៉ូនមួយមុខតែឯង ឬក៏ផ្តល់រួមជាមួយនឹងអ៊ីស្ត្រូជិន និងប្រូជេស្តេរ៉ូន។ ក៏ប៉ុន្តែ ស្ថាប័នគ្រប់គ្រងទំនិញ ព្យាបាល (TGA) មិនទាន់ផ្តល់ការអនុញ្ញាតយល់ព្រមដល់ការព្យាបាលដោយប្រើថេស្តូស្តេរ៉ូន

សម្រាប់ស្ត្រីនៅឡើយទេ។

**តើខ្ញុំអាចទទួលព័ត៌មានបន្ថែមពីកន្លែងណាខ្លះ?**

www.jeanhailes.org.au
www.healthinsite.gov.au – Health*Insite* (02) 6289 8488

**This resource was developed with the support of the Besen Family Foundation and the Australian Department of Health and Ageing**

**March 2008**